# អត្ថប្រយោជន៍បន្ថែម គ្រុបមេឌីឃែរ



## លក្ខណៈនៃផលិតផល

| | |
|---|---|
| អាយុសមាជិកដែលត្រូវបានធានា | 18 - 64ឆ្នាំ |
| រយៈពេលធានារ៉ាប់រង | 1ឆ្នាំ |

## អត្ថប្រយោជន៍ធានារ៉ាប់រង



### ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ *

ចំនួនប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ នឹងត្រូវផ្ដល់ជូនសម្រាប់ការសម្រាកព្យាបាលនៅមន្ទីរពេទ្យដោយ (ក) ជំងឺ ឬគ្រោះថ្នាក់ជាយថាហេតុ ឬ (ខ) គ្រោះថ្នាក់ជាយថាហេតុ ដោយផ្អែកទៅតាមគម្រោងដែលបានជ្រើសរើស គុណជាមួយនឹងចំនួនថ្ងៃសម្រាកព្យាបាលនៅមន្ទីរពេទ្យជាក់ស្ដែង។



### អត្ថប្រយោជន៍សម្រាប់ការវះកាត់ *

អត្ថប្រយោជន៍សម្រាប់ការវះកាត់ នឹងត្រូវផ្ដល់ជូនសម្រាប់ការវះកាត់ដោយ (ក) ជំងឺ ឬគ្រោះថ្នាក់ជាយថាហេតុ ឬ (ខ) គ្រោះថ្នាក់ជាយថាហេតុ ដោយផ្អែកទៅតាមគម្រោងដែលបានជ្រើសរើស។



### អត្ថប្រយោជន៍សម្រាប់ជំងឺគ្រុនឈាម/គ្រុនចាញ់ *

អត្ថប្រយោជន៍សម្រាប់ជំងឺគ្រុនឈាម/គ្រុនចាញ់នឹងត្រូវផ្ដល់ជូន នៅពេលធ្វើរោគវិនិច្ឆ័យរកឃើញជំងឺគ្រុនឈាម/គ្រុនចាញ់ សម្រាកព្យាបាលនៅមន្ទីរពេទ្យដោយជំងឺគ្រុនឈាម/គ្រុនចាញ់ ឬមរណភាពដោយជំងឺគ្រុនឈាម/គ្រុនចាញ់ ដោយផ្អែកទៅតាមគម្រោងដែលបានជ្រើសរើស។

*រយៈពេលរង់ចាំត្រូវបានអនុវត្ត!

# តារាងអត្ថប្រយោជន៍ធានារ៉ាប់រង

| គម្រោង | A | B | C | D | E |
|---|---|---|---|---|---|
| ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ (ដុល្លារអាមេរិក) | 10 | 15 | 25 | 50 | 75 |
| ចំនួនថ្ងៃអតិបរមាសម្រាប់ការសម្រាកពេទ្យម្តង | 20 | 20 | 20 | 30 | 45 |
| ចំនួនថ្ងៃអតិបរមាសម្រាប់ការសម្រាកពេទ្យក្នុងមួយឆ្នាំ | 60 | 60 | 60 | 90 | 120 |
| អត្ថប្រយោជន៍សម្រាប់ការវះកាត់ (ដុល្លារអាមេរិក) | 150 | 250 | 500 | 750 | 1,000 |
| អត្ថប្រយោជន៍នៅពេលធ្វើរោគវិនិច្ឆ័យរកឃើញជំងឺគ្រុនឈាម/គ្រុនចាញ់ (ដុល្លារអាមេរិក) | 50 | 50 | 100 | 150 | 200 |
| អត្ថប្រយោជន៍សម្រាប់ការសម្រាកពេទ្យដោយជំងឺគ្រុនឈាម/គ្រុនចាញ់ (ដុល្លារអាមេរិក) | 200 | 200 | 300 | 500 | 750 |
| សំណងមរណភាពដោយជំងឺគ្រុនឈាម/គ្រុនចាញ់ (ដុល្លារអាមេរិក) | 2,000 | 2,000 | 3,000 | 5,000 | 7,500 |
| ទឹកប្រាក់ត្រូវបានធានា (ដុល្លារអាមេរិក) | 3,400 | 3,900 | 6,300 | 12,300 | 20,400 |

ចំណាំ៖ ខ្លឹមសារក្នុងខិត្តប័ណ្ណផ្សព្វផ្សាយនេះគឺជាការពណ៌នាដោយសង្ខេប។ សម្រាប់ព័ត៌មានលម្អិតនៃការធានារ៉ាប់រង រួមមានអត្ថប្រយោជន៍ធានារ៉ាប់រង ករណីមិនធានា និងលក្ខខណ្ឌនៃការបញ្ចប់កិច្ចសន្យា សូមអានខ និងលក្ខខណ្ឌធានារ៉ាប់រង។

# ករណីមិនធានា

**ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ និងអត្ថប្រយោជន៍សម្រាប់ការវះកាត់ (ដោយជំងឺ ឬគ្រោះថ្នាក់ជាយថាហេតុ)**

(១) សមាជិកដែលត្រូវបានធានាចូលសម្រាកព្យាបាល ឬ ការវះកាត់ធ្វើឡើងក្នុងព្រះរាជាណាចក្រកម្ពុជា ប្រទេសចិន ប្រទេសថៃ ប្រទេសវៀតណាម ប្រទេសសិង្ហបុរី ឬ ប្រទេសម៉ាឡេស៊ី

(២) ស្ថានភាពដែលមានពីមុនស្រាប់ មុនកាលបរិច្ឆេទចាប់ផ្តើមសុពលភាពនៃបណ្ណសន្យារ៉ាប់រង ឬកាលបរិច្ឆេទនៃការដាក់បន្តសុពលភាពបណ្ណសន្យារ៉ាប់រងឡើងវិញ ដោយយកកាលបរិច្ឆេទចុងក្រោយគេ។ ស្ថានភាពដែលមានពីមុនស្រាប់ មានន័យថាជាជំងឺដែលសមាជិកដែលត្រូវបានធានាបានដឹងច្បាស់ លុះត្រាតែស្ថានភាពទាំងនោះត្រូវបានប្រកាសមកកាន់ក្រុមហ៊ុន និងទទួលយកដោយក្រុមហ៊ុន។

(៣) ការធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឲ្យរបួសខ្លួនឯង ទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ។

(៤) សមាជិកដែលត្រូវបានធានាស្ថិតនៅក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬការប្រើប្រាស់ថ្នាំណាមួយ លើកលែងតែស្ថិតក្រោមការណែនាំរបស់គ្រូពេទ្យដែលមានអាជ្ញាបណ្ណចុះបញ្ជីត្រឹមត្រូវ។

**ប្រាក់ឧបត្ថម្ភប្រចាំថ្ងៃ និងអត្ថប្រយោជន៍សម្រាប់ការវះកាត់ (ដោយគ្រោះថ្នាក់ជាយថាហេតុ)**

(១) ការធ្វើអត្តឃាត ឬប៉ុនប៉ងធ្វើអត្តឃាត ឬធ្វើឲ្យរបួសខ្លួនឯង ទោះស្ថិតក្នុងស្ថានភាពផ្លូវចិត្តប្រក្រតី ឬមិនប្រក្រតីក៏ដោយ។

(២) វីរុសហ៊ីវ (HIV) និង/ឬជំងឺណាមួយដែលជាប់ទាក់ទងនឹងវីរុសហ៊ីវ (HIV) រួមទាំងជំងឺអេដស៍ និង/ឬការផ្លាស់ប្តូរ ការវិវត្តន៍ ឬការប្រែប្រួលនៃមេរោគអេដស៍។

(៣) សង្គ្រាម (មិនថាបានប្រកាស ឬមិនបានប្រកាស) សកម្មភាពលុកលុយរបស់សត្រូវបរទេស សង្គ្រាមស៊ីវិល បដិវត្តន៍ ចលនាបះបោរ ការធ្វើកូដកម្ម ការកើនឡើងប្រជាប្រិយភាព ប្រឆាំងនឹងរដ្ឋាភិបាល និងអំពើភេរវកម្ម។

(៤) ខណៈពេលដែលសមាជិកដែលត្រូវបានធានាប្រព្រឹត្តបទឧក្រិដ្ឋ ឬខណៈពេលដែលសមាជិកដែលត្រូវបានធានាកំពុងត្រូវបានចាប់ខ្លួន ឬត្រូវរងការចាប់ខ្លួន ឬកំពុងរត់គេចពីការចាប់ខ្លួន។

**អត្ថប្រយោជន៍សម្រាប់ជំងឺគ្រុនឈាម/គ្រុនចាញ់**

(១) សមាជិកដែលត្រូវបានធានាត្រូវបានធ្វើរោគវិនិច្ឆ័យរកឃើញថាមានជំងឺគ្រុនឈាម ឬគ្រុនចាញ់ ហើយចូលសម្រាកព្យាបាលនៅក្រៅព្រះរាជាណាចក្រកម្ពុជា ប្រទេសចិន ប្រទេសវៀតណាម ប្រទេសសិង្ហបុរី ឬប្រទេសម៉ាឡេស៊ី។

(២) សមាជិកដែលត្រូវបានធានាមិនបានប្រកាសប្រាប់ក្រុមហ៊ុន ឬមានចេតនាលាក់បាំងក្រុមហ៊ុនអំពីការពិតដែលសមាជិកដែលត្រូវបានធានារូបនោះធ្លាប់ធ្វើរោគវិនិច្ឆ័យរកឃើញថាមានជំងឺគ្រុនឈាម ឬគ្រុនចាញ់ ក្នុងរយៈពេល ១៤ថ្ងៃ មុនការធានារ៉ាប់រងរបស់គាត់ចាប់ផ្តើមមានសុពលភាព ហើយបានធ្វើរោគវិនិច្ឆ័យរកឃើញថាមានជំងឺគ្រុនឈាម ឬគ្រុនចាញ់ ឬចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យ បន្ទាប់ពីការធានារ៉ាប់រងរបស់គាត់មានសុពលភាព។

(៣) សមាជិកដែលត្រូវបានធានាត្រូវបានធ្វើរោគវិនិច្ឆ័យថាមានជំងឺគ្រុនឈាម ឬគ្រុនចាញ់ ក្នុងរយៈពេលរង់ចាំនៃការធានារ៉ាប់រងរបស់គាត់។

(៤) សមាជិកដែលត្រូវបានធានាចូលសម្រាកព្យាបាលនៅមន្ទីរពេទ្យដែលមិនពាក់ព័ន្ធនឹងជំងឺគ្រុនឈាម ឬគ្រុនចាញ់ ប៉ុន្តែទទួលការព្យាបាលផ្សេងទៀត ដែលការព្យាបាលនោះរាប់បញ្ចូល តែមិនកំណត់ត្រឹម ការកែសម្រស់ ការថែទាំ ឬការជួសជុលធ្មេញ ការដាំបង្គោលធ្មេញក្នុងឆ្អឹង ឬ ការដាក់ធ្មេញប៉័រស៊ឺឡែន ឬការដាក់ធ្មេញសិប្បនិម្មិតជាដើម។

ករណីមិនធានាទាំងនេះ គឺជាចំនុចសំខាន់ខ្លះៗប៉ុណ្ណោះ។ សម្រាប់ករណីមិនធានាលម្អិតទាំងស្រុង សូមពិនិត្យមើល ខ និងលក្ខខណ្ឌធានារ៉ាប់រង។